**គណៈកម្មការទន្លេមេគង្គ**

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅភ្នំពេញ**
ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម
ប្រអប់សំបុត្រលេខ ៦២៣ ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៨៥៥-២៣ ៤២៥ ៣៥៣.
ទូរសារលេខ ៨៥៥-២៣ ៤២៥ ៣៦៣

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅវៀងច័ន្ទ**
ការិយាល័យប្រធានលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ
អគារលេខ ១៨៤ ផ្លូវហ្វា ងុម សាធារណៈរដ្ឋប្រជាធិបតេយ្យ
ប្រជាមានិតឡាវ ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុងវៀងច័ន្ទ ០១០០០
ទូរស័ព្ទលេខ ៨៥៦-២១ ២៦៣ ២៦៣
ទូរសារលេខ ៨៥៦-២១ ២៦៣ ២៦៤

## ព័ត៏មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ

ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១០

# គណៈកម្មការទន្លេមេគង្គចេញផ្សាយលទ្ធផលនៃការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តស្តីអំពីផលប៉ះពាល់ផ្នែកបរិស្ថានរបស់ទំនប់វារីអគ្គិសនីស្នើនៅតាមទន្លេមេនៃទន្លេមេគង្គ

*ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ*

នៅថ្ងៃនេះ គណៈកម្មការទន្លេមេគង្គ បានចេញផ្សាយនូវរបាយការណ៍ព្រៀងចុងក្រោយស្តីអំពីការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថានដោយទំនប់វារីអគ្គិសនីដែលគេគ្រោងសាងសង់នៅតាមទន្លេមេនៃទន្លេមេគង្គ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន សិក្សាថ្លឹងថ្លែងរវាងកាលានុវត្តភាព និងហានិភ័យដែលអាចកើតមានដោយសារគំរោងសាងសង់ទំនប់វារីអគ្គិសនីទាំង ១២ នៅតាមទន្លេមេនៃទន្លេមេគង្គ ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍កាន់តែច្រើនឡើងទៅលើការសាងសង់ទំនប់វារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គនៅក្នុងប្រទេសកម្ពុជា នៅប្រទេសឡាវ និងនៅតាមព្រំដែនរវាងប្រទេសឡាវ និងប្រទេសថៃ។

លោក ជេរេមី ប៊ីត ប្រធានប្រតិបត្តិនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និយាយថា "គំរោងវារីអគ្គិសនីចំនួន ១២ នៅតាមទន្លេមេនៃទន្លេមេគង្គស្នើឡើងដោយក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនបានជំរុញគណៈកម្មការទន្លេមេគង្គរៀបចំអោយក្រុមជំនាញការធ្វើការសិក្សាមួយដែលប៉ាន់ប្រមាណអំពីផលប្រយោជន៍ ការចំណាយ និងផលប៉ះពាល់ដែលគិតបញ្ចូលទាំងឥទ្ធិពលរបស់ទំនប់

វារីអគ្គិសនីដែលត្រូវបានសាងសង់រួចហើយ និងដែលកំពុងតែសាងសង់នៅតាមទន្លេមេគង្គលើនៅប្រទេសចិន។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាននេះ គឺជាការសិក្សាមួយក្នុងចំណោមការសិក្សាដែលមានលក្ខណៈស្មុគស្មាញបំផុតដោយសិក្សាទៅលើអាងទន្លេកំរិតអន្តរជាតិមួយ ហើយកន្លងមកបានបង្ហាញនូវគុណតម្លៃនៃកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គទៅលើបញ្ហាដែលមានលក្ខណៈរសើបខ្លាំង។”

ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថានដែលមានរយៈពេល ១៤ខែនេះ សិក្សាយ៉ាងដិតដល់អំពីផលប៉ះពាល់ដែលគំរោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គអាចមានទៅលើបរិស្ថាននៅទូទាំងអាងទន្លេមេគង្គ ព្រមទាំងបានផ្តល់ជាអនុសាសន៍អំពីថាតើប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គគួរតែបន្តគំរោងឬយ៉ាងណា ប្រសិនបើប្រទេសសមាជិកសំរេចបន្តអនុវត្តគំរោងអភិវឌ្ឍន៍វារីអគ្គិសនីទាំងនេះ។

ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ប្រមូលផ្តុំនូវមតិយោបល់របស់ភាគីពាក់ព័ន្ធគ្រប់ស្រទាប់ដែលតែងតែមានទស្សនៈខុស១គ្នាទៅលើថាតើគេគួរអភិវឌ្ឍធនធានអាងទន្លេមេគង្គដោយរបៀបណា ដើម្បីអាចការពារផលប្រយោជន៍អោយប្រជាជនដែលរស់នៅ និងអាស្រ័យលើអាងទន្លេមេគង្គ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ធ្វើការផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងរបស់សាធារណៈជនអំពីបញ្ហាសំខាន់១ ហើយនិងផ្តល់ជាអនុសាសន៍ ក៏ដូចជាជម្រើសសំរាប់ប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គយកទៅពិភាក្សា នៅពេលដែលប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គត្រូវពិចារណាថ្លឹងថ្លែងរវាងផលចំណេញផ្នែកសេដ្ឋកិច្ច និងផលវិបាកផ្នែកសង្គម និងបរិស្ថានដែលអាចកើតមានដោយសារការអនុវត្តគំរោង។

លោក ជេរេមី ប៊ីត និយាយបន្ថែមទៀតថា “លទ្ធផលដែលទទួលបានពីការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថានទាំងនេះ នឹងគាំពារដល់ដំណើរការពិគ្រោះយោបល់សំរាប់គំរោងសាងសង់ទំនប់វារីអគ្គិសនីនិមួយ១។ នេះជាបញ្ញត្តិដែលតំរូវអោយធ្វើដូចដែលមានចែងនៅកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ មុនពេលដែលប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គសំរេចត្រូវបន្ត ឬមិនបន្តគំរោងសាងសង់ ហើយបើត្រូវបន្តថាតើត្រូវបន្តក្រោមល័ក្ខខ័ណ្ឌអ្វីខ្លះ។ ដំណើរការនេះ ទើបតែចាប់ផ្តើមប៉ុណ្ណោះសំរាប់ករណីគំរោងទំនប់វារីអគ្គិសនីសាយ៉ាបូរី

ដែលមានទីតាំងនៅតាមទន្លេមេនៃទន្លេមេគង្គភាគខាងជើងប្រទេសឡាវ ហើយក៏ជាគំរោងទីមួយក្នុងចំណោមគំរោងដែលបានស្នើឡើងទាំងអស់។”

ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ជាដំណើរការប្រកបដោយការចូលរួមមួយដែលត្រូវបានរៀបចំឡើងដោយក្រុមជំនាញការមួយក្រុម ហើយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ភ្នាក់ងាររដ្ឋាភិបាលមកពីប្រទេសសមាជិកទាំងបួន និងតំណាងមកពីសង្គមស៊ីវិល វិស័យឯកជន ក្រុមអ្នកសិក្សាស្រាវជ្រាវមកពីប្រទេសចិន និងភាគីពាក់ព័ន្ធដទៃទៀតបានចូលរួមនៅក្នុងដំណើរការប៉ាន់ប្រមាណនេះ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ត្រូវបានសម្របសម្រួលដោយកម្មវិធីគំនិតផ្តួចផ្តើមអំពីការអភិវឌ្ឍវារីអគ្គិសនីដោយនិរន្តរភាព ដែលជាគំនិតផ្តួចផ្តើមមួយមានលក្ខណៈជាប់ពាក់ព័ន្ធគ្នា និងធ្វើការសហការជាមួយនឹងកម្មវិធីការងារដទៃៗទៀតរបស់គណៈកម្មការទន្លេមេគង្គ។

ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ផ្តល់នូវចំណុចសំខាន់ៗអំពីវិសាលភាពដែលការអភិវឌ្ឍវារីអគ្គិសនីអាចប៉ះពាល់ធ្ងន់ធ្ងរទៅលើដំណើរធនធានធម្មជាតិប៉ះពាល់ទៅលើជលផល លើជីវៈចម្រុះទាំងក្នុងទឹក និងលើគោក ព្រមទាំងការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាជនរស់នៅ និងអាស្រ័យលើអាងទន្លេមេគង្គ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ក៏បង្ហាញពីវិសាលភាពដែលគេអាចបញ្ចៀស កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ ដោយការធ្វើផែនការអោយបានត្រឹមត្រូវផងដែរ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ថ្លឹងថ្លែងអំពីវិសាលភាពទាំងពីរនេះ ហើយបង្ហាញពីផលប្រយោជន៍ដែលអាចទាញយកបានដូចជាថាមពលអគ្គិសនីប្រមាណជា ១៣.៥០០ មេហ្គាវ៉ាត់ ពីការអភិវឌ្ឍវារីអគ្គិសនី។ ផលចំណេញពីការអភិវឌ្ឍវារីអគ្គិសនី នឹងបង្កើនកំណើនសេដ្ឋកិច្ចជាតិ និងអាចយកទៅចំណាយលើកម្មវិធីកាត់បន្ថយភាពក្រីក្រ និងកម្មវិធីសេដ្ឋកិច្ច សង្គមផ្សេងៗ ទៀត។ ថាមពលវារីអគ្គិសនីអាចជួយកាត់បន្ថយការបំភាយឧស្ម័នកាបូនិច ទៅក្នុងខ្យល់ប្រសើរជាងការផលិតថាមពលអគ្គិសនីដើរដោយប្រើប្រេង ឬដោយដុតធ្យូងថ្ម។

ផលប៉ះពាល់តិច ឬច្រើន នឹងអាស្រ័យទៅលើចំនួន និងរូបសណ្ឋាននៃទំនប់វារីអគ្គិសនីប្រសិនបើគំរោងត្រូវបន្ត។ ចំណែកឯចំនួននៃអ្នករងផលប៉ះពាល់វិញនឹងអាស្រ័យច្រើនទៅលើទំហំដែលគំរោងទាំងនោះនឹងប៉ះពាល់ដល់ត្រីដែលធ្វើបំលាស់ទី ជាងការប៉ះពាល់ទៅលើការជម្លៀសសហគមន៍

ទៅកន្លែងដទៃ ពីព្រោះប្រជាជនក្រីក្រភាគច្រើនដែលរស់នៅតាមអាងទន្លេមេគង្គ អាស្រ័យលើការនេសាទត្រីសំរាប់ជីវភាពប្រចាំថ្ងៃ និងសំរាប់ជីវជាតិប្រូតេអ៊ីន។ ប្រជាជនជាង ១ លាននាក់ នឹងត្រូវប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលដោយសារការអភិវឌ្ឍវារីអគ្គិសនីដែលស្នើរឡើង ប្រសិនបើគំរោងត្រូវបន្ត។

ហានិភ័យធំមួយដូចដែលបង្ហាញនៅក្នុងរបាយការណ៍ចុងក្រោយរបស់ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន គឺទាក់ទងនឹងការបែងចែកការចំណាយ និងផលចំណេញរវាងប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ ជាមួយនិងសហគមន៍មូលដ្ឋាន។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បង្ហាញកង្វល់ថាផលប្រយោជន៍ជាតិ នឹងត្រូវប្រើដើម្បីដោះស្រាយអោយបានពេលលេញចំពោះផលប៉ះពាល់ទៅលើសហគមន៍តាមដងទន្លេដែលនឹងរងការប៉ះពាល់ និងដែលងាយរងគ្រោះ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ក៏បានដាក់គំរោងស្នើសាងសង់វារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គ ទៅក្នុងបរិបទនៃផលប៉ះពាល់ដែលមានកំរិតឆ្លងប្រទេស និងកើនឡើងបន្តិចម្តង១ ដោយសារការសាងសង់ទំនប់វារីអគ្គិសនីកាន់តែច្រើនឡើង នៅតាមដៃទន្លេមេគង្គក្រោម ក៏ដូចជាការសាងសង់ទំនប់វារីអគ្គិសនីនៅតាមទន្លេមេគង្គលើប្រទេសចិន។

ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន លើកឡើងនូវជម្រើសបួន សំរាប់ការអភិវឌ្ឍវារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គ។ ជម្រើសសំរាប់គំរោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គទាំងនេះ មានចាប់ពី “បញ្ឈប់ការសាងសង់ទំនប់ទាំងអស់” រហូតដល់ជម្រើស “ការអភិវឌ្ឍជំរុញដោយទីផ្សារ”។ ជាមួយនឹងជម្រើសទាំងនេះ ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានផ្តល់ជាអនុសាសន៍មួយក្នុងចំណោមអនុសាសន៍សំខាន់១ថាប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ គួរតែពិចារណាជម្រើសទី២ “ធ្វើសេចក្តីសម្រេចផ្អាកគំរោងសាងសង់ទំនប់វារីអគ្គិសនីទាំងអស់ក្នុងរយៈពេលកំណត់មួយ”។ ក្រុមជំនាញការដែលធ្វើការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានផ្តល់ជាយោបល់ថា ដោយសារតែមានភាពមិនច្បាស់លាស់ទាក់ទងនឹងទំហំ និងហានិភ័យ មិនអាចដោះស្រាយបានដែលមាននៅក្នុងប្រព័ន្ធទន្លេមេគង្គដ៏ស្មុគស្មាញ គួរផ្អាកធ្វើសេចក្តីសម្រេចលើគំរោងសាងសង់ទំនប់វារីអគ្គិសនីសំរាប់រយៈពេល ១០ឆ្នាំ ដោយត្រូវពិនិត្យឡើងវិញរៀងរាល់បីឆ្នាំម្តង ដើម្បីធានាថា លក្ខខ័ណ្ឌចាំបាច់នានា ត្រូវបាន

អនុវត្តប្រកបដោយប្រសិទ្ធភាព ប្រយោជន៍ដើម្បីពង្រឹងការយល់ដឹងអំពីប្រព័ន្ធធម្មជាតិ ព្រមទាំងដំណើរការគ្រប់គ្រង និងដំណើរការត្រួតពិនិត្យប្រព័ន្ធធម្មជាតិ។

ការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានបង្ហាញពីបញ្ហាសំខាន់ៗទាក់ទិននឹងការអភិវឌ្ឍទំនប់វារីអគ្គិសនីស្នើឡើងទាំង ១២ នៅតាមទន្លេមេនៃទន្លេមេគង្គក្រោម។ ការប៉ាន់ប្រមាណនេះ ផ្តល់ជាមូលដ្ឋានគ្រឹះសំរាប់ការពិភាក្សានៅគណៈកម្មការទន្លេមេគង្គទៅលើផលប្រយោជន៍កំរិតណាដែលចាត់ទុកថាមាននិរន្តរភាព ហើយផលប៉ះពាល់កំរិតណាដែលគេអាចពិចារណាប្រសិនបើមានយន្តការសំរាប់ដោះស្រាយនោះ។ ប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ នឹងចាប់ពិភាក្សាស៊ីជម្រៅដោយមានលទ្ធផលនៃការប៉ាន់ប្រមាណជាយុទ្ធសាស្រ្តអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ជួយផ្តល់ជាការវិភាគដ៏សំខាន់សំរាប់ការពិភាក្សានៅក្នុងនីតិវិធីផ្លូវការសំរាប់ការពិគ្រោះយោបល់ជាមុនដែលគណៈកម្មការទន្លេមេគង្គជាអ្នកសម្របសម្រួល ដើម្បីពិនិត្យទៅលើគំរោងសាងសង់ទំនប់វារីអគ្គិសនី និមួយៗ ដូចជាគំរោងសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាបូរី ជាដើម។

**សំរាប់ព័ត៏មានបន្ថែម** សូមទាក់ទងអ្នកស្រី ទីហ្វានី ហាក់គ័រ ទីប្រឹក្សាផ្នែកទំនាក់ទំនងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈទូរស័ព្ទលេខ (៨៥៦-២០) ៥៦១ ២០៦៩៥ ឬលេខ (៨៦៥-២១) ២៦៣ ២៦៣ អ៊ីម៉ែល tiffany@mrcmekong.org លោក លីម ឃី មន្រ្តីផ្នែកទំនាក់ទំនងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈទូរស័ព្ទលេខ (៨៥៥-៦៧) ៥១៩ ៨៣៨

អ៊ីមែល khy@mrcmekong.org

## ព័ត៏មានបន្ថែមសំរាប់និពន្ធនាយក:

កំណើនចំណាប់អារម្មណ៍លើការអភិវឌ្ឍទន្លេមេនៃទន្លេមេគង្គ កើតមានបន្ទាប់ពីប្រទេសចិនបានបញ្ចាប់ការសាងសង់ទំនប់វារីអគ្គិសនីចំនួនបីនៅទន្លេមេគង្គលើ។ ការបញ្ចាប់ការសាងសង់វារីអគ្គិសនីនៅចិន បានធ្វើអោយមានកំណើនធារទឹកនៅរដូវប្រាំងនៅតាមទន្លេមេគង្គក្រោម ហើយបានបង្កើតសក្តានុពលសំរាប់ការអភិវឌ្ឍវារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គក្រោម ព្រមទាំងបានបង្កើនការយកចិត្តទុកដាក់របស់សកលលោកទៅលើការកាត់បន្ថយបំភាយឧស្ម័នកាបូនិចទៅក្នុងបរិយាកាសដោយសារការផលិតថាមពលវារីអគ្គិសនី។ គំរោងភាគច្រើន ត្រូវបានផ្តួចផ្តើមឡើងជាង ១៥ឆ្នាំមក

ហើយ ប៉ុន្តែទើបតែពេលថ្មីៗនេះទេ ដែលចំណាប់អារម្មណ៍របស់ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជននាំទៅដល់ការស្នើគំរោងអភិវឌ្ឍន៍វារីអគ្គិសនីទាំង ១២ ដែលពេលសព្វថ្ងៃនេះបានឈានដល់ជំហានធ្វើការសិក្សារកលទ្ធភាពសាងសង់បានឬមិនបាន។

គណៈកម្មការទន្លេមេគង្គ ជាស្ថាប័នអន្តររដ្ឋាភិបាល របស់ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសថៃ និងប្រទេសវៀតណាម។ គណៈកម្មការទន្លេមេគង្គ មានភារៈកិច្ចទទួលខុសត្រូវចំពោះកិច្ចប្រតិបត្តិការលើការគ្រប់គ្រងលើអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព។ គណៈកម្មការទន្លេមេគង្គ ធ្វើការងារលើវិស័យផ្សេងៗដែលពាក់ព័ន្ធនឹងទន្លេ ក្នុងនោះរួមមានការគ្រប់គ្រងជលផល ប្រកបដោយនិរន្តរភាព ការស្វែងរកកាលានុវត្តភាពសំរាប់ការអភិវឌ្ឍវិស័យកសិកម្ម ការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាព និងការរក្សាអោយបាននូវសេរីភាពនាវាចរណ៍ ការគ្រប់គ្រងទឹកជំនន់ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី។ បន្ថែមលើវិស័យផ្សេងៗខាងលើ គឺឥទ្ធិពលនៃទឹកជំនន់ធំៗ គ្រោះរាំងស្ងួតរយៈពេលយូរច្រើនជាងមុន និងការកើនឡើងនូវកំរិតទឹកសមុទ្របង្ករឡើងដោយការប្រែប្រួលអាកាសធាតុ។ គណៈកម្មការទន្លេមេគង្គ ផ្តល់ជាជំបូន្មានក្នុងការសម្របសម្រួលកិច្ចចរចាររវាងរដ្ឋាភិបាល ជាមួយនឹងវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីរកដំណោះស្រាយលើបញ្ហាប្រឈមមុខខាងលើ។